ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ
វាយតំលៃនិងប្រគល់កិច្ចសន្យា គបវប (PEAC)
លេខ : 857 PEAC. អក

រាជធានីភ្នំពេញ , ថ្ងៃទី 24 ខែ ធ្នូ ឆ្នាំ 2013

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដេញថ្លៃផ្គត់ផ្គង់ប្រេងសាំងធម្មតា និង ប្រេង DO សំរាប់រដ្ឋបាល EDC ប្រើប្រាស់ក្នុងឆ្នាំ 2014

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនផ្គត់ផ្គង់ប្រេងឥន្ធនៈ ( គិតទាំងសហគ្រាសឯកត្តបុគ្គល ) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា : អគ្គិសនីកម្ពុជានឹងដាក់អោយដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ប្រេងសាំងធម្មតា និងប្រេង DO សំរាប់រដ្ឋបាល EDC ប្រើប្រាស់ក្នុងឆ្នាំ 2014 ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ក្រុមហ៊ុនបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម អាស័យដ្ឋានផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ ចាប់ពី *ថ្ងៃទី 26 ខែ ធ្នូ ឆ្នាំ 2013* តទៅរៀងរាល់ម៉ោងធ្វើការ ។

ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹម *ថ្ងៃទី 21 ខែ មករា ឆ្នាំ 2014 វេលាម៉ោង 14:00 រសៀល* ។

ការបើកឯកសារដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាស័យដ្ឋានខាងលើ វេលាម៉ោង *15:00 ថ្ងៃទី 21 ខែ មករា ឆ្នាំ 2014* ។

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជា ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័តមានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

សូមទាក់ទង
ទូរស័ព្ទលេខ : 016 921 117

ចំលងជូន :
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
" នាយកដ្ឋានលទ្ធកម្មសាធារណៈ "